ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ២០៦៤៧ សរណ.អកក.អស

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ផ្លាស់ប្តូរ តម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្គលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងលេខ ប.ត046 ស្ថិតនៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស ក្នុងសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា (២)តំបន់ភ្លើងលេខ ប.ត083 ស្ថិតនៅតាមបណ្តោយផ្លូវលេខ៥១ ក្នុងសង្កាត់បឹងរាំង ខណ្ឌដូនពេញ (៣)តំបន់ភ្លើងលេខ ប.ត467 ស្ថិតនៅតាមបណ្តោយផ្លូវលេខ១៦៣ ក្នុងសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា (៤)តំបន់ភ្លើងលេខ P064 ស្ថិតនៅភូមិថ្មគោល ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (៥)តំបន់ភ្លើងលេខ P431 ស្ថិតនៅភូមិជ្រៃកោង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

២. ថ្ងៃសុក្រទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងលេខ D09 ស្ថិតនៅតាមបណ្តោយផ្លូវលេខ៣១៤ ក្នុងសង្កាត់បឹងកក់១ ខណ្ឌទួលគោក និង (២) តំបន់ភ្លើងលេខ P064 ស្ថិតនៅភូមិថ្មគោល ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

៣. ថ្ងៃសៅរ៍ទី២២ ខែវិច្ឆិកា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងលេខ ប.ត046 ស្ថិតនៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស ក្នុងសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា (២)តំបន់ភ្លើងលេខ ប.ត120 ស្ថិតនៅតាមបណ្តោយផ្លូវលេខ១០៦ ក្នុងសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ និង (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិទឹកថ្លា ក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភូមិគោកចំបក់ ភូមិថ្មគោល ភូមិត្រពាំងថ្លឹង ភូមិទួលពង្រ ភូមិចោមចៅ ភូមិព្រៃសណ្តែក ភូមិព្រៃល្វា ភូមិព្រៃជីសាក់ ភូមិជ្រៃកោង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

៤. ថ្ងៃអាទិត្យទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងលេខ ប.ត656 ស្ថិតនៅតាមបណ្តោយផ្លូវលេខ១០២ ក្នុងសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ (២)តំបន់ភ្លើងលេខ P876,P1238 ស្ថិតនៅក្នុងសង្កាត់សំពាង ខណ្ឌព្រែកព្នៅ (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជើងឯក ចាប់ពីភូមិសំបួរ ក្នុងសង្កាត់ដង្កោ រហូតដល់ភូមិព្រែកប្រណាក់ ក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ និង (៤)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិព្រៃល្វា ភូមិព្រៃសណ្តែក ភូមិព្រៃជីសាក់ ភូមិថ្មគោល ភូមិជ្រៃកោង ភូមិចោមចៅ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**